# របៀបអនុវត្តមុខងារ

## “ ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ ”

បាត់ដំបង ថ្ងៃទី២១-២២ ខែកញ្ញា ឆ្នាំ២០១៥

## គំនូសបំព្រួញនៃការថែទាំជំនួសចំពោះកុមាររងគ្រោះ និងងាយរងគ្រោះ និងការធ្វើអធិការកិច្ច



## ដំណើរការស្នើសុំបញ្ចូលកុមារក្នុងមណ្ឌល




III. **របៀបអនុវត្ត** “ ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ ”

១. ពិនិត្យសុំណុំឯកសារដែលសុំបញ្ចូលកុមារកំព្រា កុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងមណ្ឌលរដ្ឋដែលស្នើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច ឬអាណាព្យាបាល លិខិតស្នើសុំ១.pdf

**ក. សំណុំឯកសារបញ្ចូលកុមារក្នុងមណ្ឌល ( ឧបសម្ព័ន្ធ-១ )**

- ទម្រង់ឆ្លើយតបដំបូង ១៣០១.pdf
- ទម្រង់ប៉ាន់ប្រមាណគ្រួសារ ១៣០២.pdf
- ទម្រង់ផែនការសេវាគ្រួសារ ១៣០៣.pdf
- ទម្រង់ទុកដាក់កុមារតាមការថែទាំជំនួស ១៣០៤.pdf
- ទម្រង់ទទួលឲ្យស្នាក់នៅក្នុងមណ្ឌល ១៣០៦.pdf
- ទម្រង់របាយការណ៍អំពីកុមារដែលត្រូវបោះបង់ចោល ១៣០៧.pdf
- ទម្រង់របាយការណ៍អំពីការរកមិនឃើញឪពុកម្តាយបង្កើត ឬអាណាព្យាបាលកុមារ ១៣១២.pdf
- ទម្រង់សម្រេចបញ្ចូលកុមារក្នុងផែនការអចិន្ត្រៃយ៍ ១៣១៣.pdf

២. ចេញសេចក្ដីសម្រេចបញ្ចូលកុមារតាមការស្នើសុំរបស់អាជ្ញាធរសមត្ថកិច្ច ឬអាណាព្យាបាល




៣.សហការជាមួយមន្ទីរ ស.អ.យ ក្នុងការគ្រប់គ្រងមណ្ឌលរដ្ឋ ដោយអនុវត្តតាមប្រកាសលេខ ៦១៦ ស.អ.យ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល និងអនុក្រឹត្យលេខ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួល មាត្រា៧ នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្ដីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលរដ្ឋ និងអនុក្រឹត្យលេខ១១៦.

**៣.១. សុខុមាលភាព និងការអភិវឌ្ឍរបស់កុមារ**

- សុខភាព
  - សេវាផ្នែកវេជ្ជសាស្ត្រ
  - ការចាក់ថ្នាំបង្ការ
  - សង្គ្រោះបឋមនៅក្នុងមណ្ឌល
  - បុគ្គលិកចេះប្រើប្រាស់សម្ភារៈក្នុងការសង្គ្រោះបឋម

- ការណែនាំអំពីរបៀប ពេលវេលា និងមូលហេតុនៃការប្រើប្រាស់ថ្នាំ
- យល់ដឹងអំពីអនាម័យ (ផ្ទាល់ខ្លួន កន្លែងស្នាក់នៅ ម្ហូបអាហារ)

• អនាម័យ
- ការថែទាំអនាម័យ រួមទាំងសុខភាពមាត់ធ្មេញ
- ការប្រើប្រាស់ទឹកស្អាតសម្រាប់ទទួលទាន
- ការប្រើប្រាស់កែវទឹក
- ការប្រើប្រាស់ទឹកសម្រាប់ងូត និងបោកគក់
- ការផ្តល់សម្ភារៈងូតទឹកដល់កុមារ

• សំលៀកបំពាក់
- សំលៀកបំពាក់ និងឯកសណ្ឋាន
- សម្ភារៈដំណេក

• ចំណីអាហារ
- ការផ្តល់អាហារូបត្ថម្ភដល់កុមារ (ពេលព្រឹក ថ្ងៃត្រង់ ល្ងាច)
- របបអាហារូបត្ថម្ភមានគុណភាពដែលមានប្រូតេអីន
- របបចាំបាច់សម្រាប់កុមារដែលមានតម្រូវការពិសេស (ទារក ពិការ មានជំងឺ ជំនឿសាសនា)

៣.២. ការអភិវឌ្ឍន៍ផ្នែកសង្គម និងផ្នែកវប្បធម៌

• ការអភិវឌ្ឍន៍ផ្នែកសង្គម
- សេរីភាពក្នុងការចូលរួមបញ្ចេញមតិយោបល់
- សកម្មភាពចូលរួមផ្សេងៗ
- សិទ្ធយល់ដឹង និងសិទ្ធរក្សាបាននូវអត្តសញ្ញាណរបស់ខ្លួន
- ឱកាសទទួលបានការពិគ្រោះយោបល់
- ការលើកទឹកចិត្តឲ្យចេះស្រឡាញ់រាប់អានគ្នា
- ការអនុញ្ញាតិឲ្យមានទំនាក់ទំនង
- ថវិកាទៅលេងសាច់ញាតិ
- សេរីភាពក្នុងការចេញចូលមណ្ឌល

- ផ្នែកវប្បធម៌
  - ឱកាសចូលរួមក្នុងសកម្មភាពផ្នែកសាសនា
  - ឱកាសចូលរួមក្នុងសកម្មភាពកំសាន្តផ្សេងៗ

៣.៣. ការសិក្សាអប់រំ

- ការអប់រំជាមូលដ្ឋាន
- ការអប់រំក្នុងប្រព័ន្ធ ឬក្រៅប្រព័ន្ធទាំងក្នុងសាលារដ្ឋ សាលាឯកជន ឬក្នុងមណ្ឌល
- ការជ្រើសរើស និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការអប់រំពីវិធីផ្សេងៗ (សិទ្ធិ សីលធម៌ អនាម័យ... ការពារខ្លួន...)
- សម្ភារៈចាំបាច់សម្រាប់សិក្សា
- ចំពោះកុមារដែលត្រូវបោះបង់សាលា មណ្ឌល (ជំរុញ លើកទឹកចិត្ត)

៣.៤. ការចូលរួម

- សិទ្ធិចូលរួមសម្រេចចិត្តក្នុងការធ្វើផែនការអនាគត
- សេចក្តីសម្រេចដែលពាក់ព័ន្ធ (ស្វែងរកគ្រួសារ ធ្វើសមាហរណកម្ម សិវត្តិភាព សុខុមាលភាព)
- សិទ្ធិចូលរួមសកម្មភាពប្រចាំថ្ងៃ
- សិទ្ធិស្វែងយល់ អំពីអនុសញ្ញាសិទ្ធិកុមារ និងបទដ្ឋានអប្បរមា
- សិទ្ធិពេញលេញ និងរក្សាការសំងាត់
- ការជំរុញលើកទឹកចិត្ត
- ការណែនាំឲ្យចូលរួមធ្វើកិច្ចការផ្ទះប្រចាំថ្ងៃ
- ការការពារពីភាពរើសអើង
- ផ្តល់ប្រឹក្សាដល់កុមារ
- មានឯកសារ និងសម្ភារៈសមស្រប

- លើកទឹកចិត្តឲ្យចូលរួម (ថ្ងៃបុណ្យ.... ចែកសញ្ញាបត្រ... )
- អនុញ្ញាតឲ្យចូលរួមក្នុងពិធី (រៀបអាពាហ៍ពិពាហ៍....)
- ការបំផុសលើកទឹកចិត្ត
- ការផ្តល់លទ្ធភាពឲ្យជ្រើសរើសសកម្មភាពនានា
- ការអនុញ្ញាតឲ្យឈប់ពីការចូលរួមសកម្មភាពនានា
- ជំនួយផ្សេងៗដែលជាតម្រូវការរបស់កុមារពិការ

## ៣.៥. ការដាក់វិន័យចំពោះកុមារ

- ការដាក់វិន័យដែលនាំឲ្យមានផលប៉ះពាល់ដល់ការអភិវឌ្ឍន៍របស់កុមារ
- ត្រូវលើកទឹកចិត្ត
- ការដាក់វិន័យលើកុមារនៅពេលកុមារមិនគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់មណ្ឌល
- មិនត្រូវវាយតម្លៃបន្តុះបន្ទាប់
- បុគ្គលិកត្រូវគោរពបទបញ្ជាផ្ទៃក្នុង និងធ្វើជាគំរូល្អដល់កុមារ

## ដំណើរការស្នើសុំបច្ចេញកុមារពីមណ្ឌល



៤.ពិនិត្យសុំណុំឯកសារដែលសុំបញ្ចេញកុមារកំព្រា កុមាររងគ្រោះ និងងាយរងគ្រោះពីមណ្ឌល រដ្ឋដែលស្នើឡើងដោយប្រធានមណ្ឌល លិខិតស្នើសុំ២.pdf

**ខ.សំណុំឯកសារបញ្ចេញកុមារពីមណ្ឌល (មើលឧបសម្ព័ន្ធ១.សៀវភៅណែនាំ)**

- ទម្រង់របាយការណ៍នៃការរកឃើញឪពុកម្តាយបង្កើត ឬអាណាព្យាបាលកុមារ ១៣០៨.pdf
- ទម្រង់ប៉ាន់ប្រមាណគ្រួសារដើម្បីបង្រួបបង្រួមគ្រួសារ ១៣០៩.pdf
- ទម្រង់បញ្ជាក់ពីការប្រគល់កុមារជូនឪពុកម្តាយបង្កើត ឬអាណាព្យាបាល ១៣១០.pdf
- ទម្រង់របាយការណ៍អំពីកុមារចាកចេញពីការថែទាំជំនួស ១៣១១.pdf
- ទម្រង់អន្តរកាលពីការទុកដាក់បណ្តោះអាសន្នជាមួយសាច់ញាតិទៅទុកដាក់អចិន្ត្រៃយ៍ជាមួយសាច់ញាតិ ១៣២០.pdf
- ទម្រង់បញ្ជាក់អំពីការប្រគល់កុមារទៅឲ្យឪពុកម្តាយចិញ្ចឹម ឬអាណាព្យាបាលជាផ្លូវការ ១៣២៧.pdf

៥. ចេញសេចក្តីសម្រេចបញ្ចេញកុមារពីមណ្ឌលតាមការស្នើសុំរបស់ប្រធានមណ្ឌល



៦.សហការជាមួយមន្ទីរ ស.អ.យ ក្នុងការចាត់ចែងមន្ត្រីដើម្បីទទួលខុសត្រូវការគ្រប់គ្រងករណីកុមារនៅក្នុងមណ្ឌល ធ្វើសមាហរណកម្ម បង្រួបបង្រួមគ្រួសារ ធ្វើការតាមដាន និងបិទករណីកុមារ

៧.សហការជាមួយមន្ទីរ ស.អ.យ ក្នុងការរៀបចំផែនការអចិន្ត្រៃយ៍សម្រាប់កុមារនៅក្នុងមណ្ឌលរដ្ឋខេត្តបាត់ដំបង ដើម្បីរកគ្រួសារឲ្យកុមារ ដោយអនុវត្តតាម ជំពូកទី៧ ការធ្វើផែនការអចិន្ត្រៃយ៍ នៅត្រង់ប្រការ ២៤ នៃប្រកាសលេខ ២២៨០ ស.អ.យ ចុះថ្ងៃទី១១ខែតុលា ឆ្នាំ២០១១ ដែលមានទម្រង់ និងលិខិតដូចជា៖ (ឧបសម្ព័ន្ធ-២)

- ទម្រង់សម្រេចបញ្ចូលកុមារក្នុងផែនការអចិន្ត្រៃយ៍ ១៣១៣.pdf
- ទម្រង់ពិគ្រោះយោបល់ជាមួយឪពុកម្តាយ/អ្នកអាណាព្យាបាលអំពីសុំកូន១៣១៤.pdf

- ទម្រង់បញ្ជាក់អំពីការយល់ព្រមរបស់ឪពុកម្តាយបង្កើត/អ្នកអាណាព្យាបាលអំពីសុំកូន ១៣១៥.pdf
- ទម្រង់បញ្ជាក់អំពីការពិគ្រោះយោបល់ជាមួយកុមារអំពីសុំកូន ១៣១៦.pdf
- ទម្រង់ពាក្យសុំសម្រាប់សុំកូនក្នុងប្រទេស ១៣២២.pdf
- ទម្រង់របាយការណ៍ប៉ាន់ប្រមាណដល់លំនៅឋានអ្នកសុំអំពីលទ្ធភាពធ្វើជាឪពុកម្តាយចិញ្ចឹម ១៣២៥.pdf
- ទម្រង់របាយការណ៍អំពីការផ្គូរផ្គងកុមារជាមួយអនាគតឪពុកម្តាយចិញ្ចឹម ឬអាណាព្យាបាល ១៣២៦.pdf

- លិខិតឯកភាពយល់ព្រមចំពោះសុំកូនដោយឪពុកម្តាយ ឬអាណាព្យាបាល A.pdf
- លិខិតឯកភាពយល់ព្រមចំពោះសុំកូនដោយកុមារផ្ទាល់ B.pdf
- លិខិតបដិសេធសំណើរបស់កុមារដោយសាម៉ីអ្នកសុំ C.pdf
- លិខិតទទួលសំណើរបស់កុមារដោយសាម៉ីអ្នកសុំ D.pdf

៨.ផ្សព្វផ្សាយការយល់ដឹងអំពីគោលនយោបាយ និងប្រកាសស្តីពីការថែទាំជំនួសចំពោះកុមារដល់មន្ត្រីក្រោមឪវាទ និងប្រជាជនក្នុងភូមិសាស្ត្រខេត្តបាត់បំបង

៩.សហការជាមួយមន្ទីរ ស.អ.យ ក្នុងការបណ្តុះបណ្តាលបំណិនជីវិត និងជំនាញវិជ្ជាជីវៈនានា សម្រាប់កុមារអាយុច្រើនដែលមិនអាចរកគ្រួសារអចិន្ត្រៃយ៍បាន មុនពេលពួកគេឈានដល់ភាពពេញវ័យ

១០.បំពេញបញ្ជីបច្ចុប្បន្នភាពកុមារនៅក្នុងមណ្ឌលរដ្ឋ និងសំណុំឯកសារដែលត្រូវសុំកូនផ្ញើមកក្រសួង ស.អ.យ មាន៖ (ឧបសម្ព័ន្ធ-៣)

- បញ្ជីបច្ចុប្បន្នភាពកុមារក្នុងមណ្ឌល បញ្ជីបច្ចុប្បន្នភាពកុមារក្នុងមណ្ឌល.pdf
- តារាងត្រួតពិនិត្យឯកសារករណីកុមារ តារាងត្រួតពិនិត្យឯកសារករណីកុមារ.pdf

១១.ធ្វើរបាយការណ៍បូកសរុបលទ្ធផលការអនុវត្តមុខងារប្រចាំខែ ត្រីមាស និងឆ្នាំជូន ក្រុមប្រឹក្សាខេត្តបាត់ដំបង និងផ្ញើជូនក្រសួង ស.អ.យ តាមរយៈមន្ទីរ ស.អ.យ ខេត្តបាត់ដំបង